**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# មតិសំណេះសំណាល

## របស់ឧបនាយករដ្ឋមន្ត្រី គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រធានគណៈកម្មការមូលបត្រកម្ពុជា

## ក្នុងពិធីសម្ពោធក្រុមហ៊ុនមូលបត្រ Golden Fortune (Cambodia) Securities Plc

## រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១១

- ឯកឧត្តមនាយឧត្តមសេនីយ៍ **មាស សុផា** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក
- ឯកឧត្តម លោកជំទាវសមាជិក-សមាជិកានៃរាជរដ្ឋាភិបាលកម្ពុជា
- លោក **Jin Yuan** តំណាងឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
- លោក **ចាង យុនហ្វេង** ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុនមូលបត្រ Golden Fortune (Cambodia) Securities Plc
- ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោកស្រី អស់លោក ជាទីមេត្រី !

ថ្ងៃនេះ ខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយត្រូវបានអញ្ជើញជាអធិបតីនៅក្នុងពិធីសម្ពោធដ៏អធិកអធមនៃក្រុមហ៊ុនមូលបត្រ Golden Fortune (Cambodia) Securities Plc ដែលជាក្រុមហ៊ុនពាណិជ្ជករមូលបត្រមួយក្នុងចំណោមក្រុមហ៊ុនពាណិជ្ជករមូលបត្រ (Securities Dealer) ចំនួន ២ ដែលទទួលបានអាជ្ញាបណ្ណកាលពីពេលកន្លងទៅនេះពីគណៈកម្មការមូលបត្រកម្ពុជា ។

ជាការពិតណាស់ ការសម្ពោធបើកក្រុមហ៊ុនមូលបត្រ Golden Fortune (Cambodia) Securities Plc ជាផ្លូវការថ្ងៃនេះ និងការសម្ពោធដាក់ឱ្យដំណើរការក្រុមហ៊ុនពាណិជ្ជករមូលបត្រដទៃទៀត ក្រុមហ៊ុនធានាទិញ (Securities Underwriter) និងក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ (Securities Broker) នាពេលកន្លងមក ជាសក្ខីភាពនៃការត្រៀមខ្លួនរួចរាល់របស់អន្តរការីមូលបត្រ ដែលជាផ្នែកមួយមិនអាចខ្វះបាននៃហេដ្ឋារចនាសម្ព័ន្ធសម្រាប់ទ្រទ្រង់ដល់ភាពជោគជ័យនៃគម្រោងដាក់ឱ្យដំណើរការទីផ្សារមូលបត្រកម្ពុជានាពេលដ៏ខ្លីខាងមុខ នៅ

ក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនពាណិជ្ជករមូលបត្រ មានតួនាទីដ៏សំខាន់ក្នុងការជួញដូរមូលបត្រនៅក្នុងទីផ្សារបន្ទាប់ (Secondary Market) តាមរយៈប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (CSX) ដោយមិនត្រឹមតែផ្តល់សេវាជើងសាមូលបត្រដល់សាធារណជន ដែលធ្វើការវិនិយោគទិញ-លក់មូលបត្រប៉ុណ្ណោះទេ ថែមទាំងអាចជួញដូរមូលបត្រ លើគណនីផ្ទាល់ខ្លួន ដោយរ៉ាប់រងលើហានិភ័យដោយខ្លួនឯងទៀតផង។ តាមរយៈតួនាទីទាំងនេះ ក្រុមហ៊ុនពាណិជ្ជករមូលបត្រ គឺជាចលករដ៏សំខាន់ក្នុងប្រតិបត្តិការជួញដូរលើទីផ្សារប្រចាំថ្ងៃ ដោយមិនត្រឹមតែធ្វើឱ្យមានជវភាព (Dynamic) នៅក្នុងដំណើរការជួញដូរប៉ុណ្ណោះទេ ថែមទាំងបង្កើតឱ្យមាននូវសន្ទនីយភាព (Liquidity) នៅក្នុងទីផ្សារទៀតផង។

**ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោកស្រី អស់លោក**

គួរគូសបញ្ជាក់ផងដែរថា ការបង្កើត និងដាក់ឱ្យដំណើរការទីផ្សារមូលបត្រនៅកម្ពុជា មិនមែនជារឿងចៃដន្យនោះទេ គឺឆ្លងកាត់ការរៀបចំ និងការគិតគូរល្អិតល្អន់ប្រកបដោយវិចារណកម្មច្បាស់លាស់ ហើយមានកំណត់យ៉ាងច្បាស់នៅក្នុង "**យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ ២០០៦-២០១៥**" របស់រាជរដ្ឋាភិបាល និង "**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ២** " សម្រាប់ កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ជាមួយគ្នានៃការវិវត្តនៃក្របខណ្ឌច្បាប់និងសេដ្ឋកិច្ចកម្ពុជា ក៏ដូចជា បម្លាស់ប្តូរនៃបរិការណ៍តំបន់និងពិភពលោកនាពេលបច្ចុប្បន្ន "**យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ ២០០៦-២០១៥**" ក៏បានធ្វើបច្ចុប្បន្នកម្មទៅជា "**យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ ២០១១-២០២០**" ផងដែរ។

ដូចឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោកស្រី អស់លោក បានជ្រាបស្រាប់ហើយថា ដើម្បីធានាស្ថេរភាពសមិទ្ធផល ក៏ដូចជាការរីកចម្រើននៃសេដ្ឋកិច្ចរូបវន្តនៅកម្ពុជា ជាពិសេសជំរុញឱ្យការអភិវឌ្ឍសេដ្ឋកិច្ចជាតិឈានដល់កម្រិតសក្តានុពល ប្រព័ន្ធហិរញ្ញវត្ថុកម្ពុជាត្រូវមានភាពរឹងមាំ និងប្រសិទ្ធភាព ដែលក្នុងនោះអត្ថិភាពនៃទីផ្សារមូលបត្រមានភាពចាំបាច់ខានមិនបាន ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់នូវយន្តការហិរញ្ញប្បទានបំពេញបន្ថែមទៅលើប្រព័ន្ធធនាគារដែលមានស្រាប់។

ដើម្បីឈានដល់គោលដៅទាំងនេះ ជាពិសេស ដើម្បីឱ្យទីផ្សារមូលបត្រផ្តល់នូវវិភាគទានជាផ្លែផ្កាប្រកបដោយភាពរឹងមាំ និងយូរអង្វែងដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ក៏ដូចជាសេដ្ឋកិច្ចរូបវន្តនៃកម្ពុជា លុះត្រាតែធាតុទាំងអស់នៅក្នុងប្រព័ន្ធនិម្មាបនិកកម្មទីផ្សារមូលបត្រ (Market Architecture) ដែលរួមមានទាំងផ្នែកទន់ (Soft) និងផ្នែករូបវន្ត (Hard) ព្រមទាំងតួអង្គពាក់ព័ន្ធមានគុណភាពល្អ មានជំនាញ និងវិជ្ជាជីវៈខ្ពស់ ជាពិសេសមានការត្រៀមខ្លួនបានល្អ មានឆន្ទៈ និងមានទិសដៅអាជីវកម្មយូរអង្វែង ត្តយ៉ាងនៅថ្ងៃនេះ យើងទាំងអស់គ្នាចូលរួមសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការនូវក្រុមហ៊ុនមូលបត្រ Golden Fortune (Cambodia)

Securities Plc ដែលជាក្រុមហ៊ុនបង្កើតឡើងដោយធុរជនឈានមុខ និងមានឆន្ទៈចូលរួមក្នុងកិច្ចអភិវឌ្ឍទីផ្សារមូលបត្រនៅកម្ពុជាតាំងពីដើមទី ដោយមិនត្រឹមតែបានបណ្តាក់ទុនវិនិយោគ រៀបចំហេដ្ឋារចនាសម្ព័ន្ធចាំបាច់ពាក់ព័ន្ធប៉ុណ្ណោះទេ ថែមទាំងបានខិតខំស្វះស្វែងរកដៃគូ និងបុគ្គលិកគ្រប់គ្រងដែលមានជំនាញ និងបទពិសោធន៍ខ្ពស់ក្នុងវិស័យមូលបត្រមកពីបរទេស ជាពិសេសមានបុគ្គលិកជំនាញដែលធ្លាប់ចូលរួមក្នុងកិច្ចដំណើរការអភិវឌ្ឍទីផ្សារមូលបត្រនៃប្រទេសចិនពីដំបូងទីទៀតផង ដូចដែលលោក **ចាង យុនហ្វេង** បានបញ្ជាក់ពីខាងដើម។

ជាមួយនឹងឆន្ទៈដ៏មុតមាំរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការដាក់ឱ្យដំណើរការទីផ្សារមូលបត្រ និងជាពិសេសស្ថិតក្រោមអគ្គមគ្គុទ្ទេសក៍ណែនាំដ៏ខ្ពង់ខ្ពស់ជាប្រចាំរបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** ពិសេសពាក់ព័ន្ធនឹងការកំណត់គោលនយោបាយក្នុងវិស័យមូលបត្រ តួអង្គពាក់ព័ន្ធក្នុងប្រព័ន្ធទីផ្សារមូលបត្រ រួមមាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សហគ្រាសរដ្ឋ និងតួអង្គពាក់ព័ន្ធដទៃទៀតក្នុងប្រព័ន្ធទីផ្សារមូលបត្រ កំពុងបំពេញការងារយ៉ាងសកម្មតាមភារកិច្ចរៀងៗខ្លួន ដោយយកចិត្តទុកដាក់ ស្មារតីទទួលខុសត្រូវ និងកិច្ចសហប្រតិបត្តិការខ្ពស់ ដើម្បីឱ្យការដាក់ដំណើរការទីផ្សារមូលបត្រប្រព្រឹត្តទៅប្រកបដោយជោគជ័យ និងឱ្យកិច្ចដំណើរការនៃទីផ្សារមូលបត្រនៅកម្ពុជាគោរពតាមច្បាប់ និងបទប្បញ្ញត្តិ និងប្រកបដោយ **តម្លាភាព គណនេយ្យភាព សុវត្ថិភាព ប្រសិទ្ធភាព និងយុត្តិធម៌** ក្នុងគោលដៅ**ការពារផលប្រយោជន៍វិនិយោគិនសាធារណៈ** និងធ្វើឱ្យទីផ្សារមូលបត្រអាចផ្តល់នូវវិភាគទានជាផ្លែផ្កា ប្រកបដោយភាពរឹងមាំ និងយូរអង្វែងដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ក៏ដូចជាសេដ្ឋកិច្ចរួបវន្តនៅកម្ពុជា ដែលកត្តាទាំងនេះ ទាមទារឱ្យកិច្ចការដាក់ឱ្យដំណើរការទីផ្សារមូលបត្រមានការរៀបចំច្បាស់លាស់ និងមានការគិតគូរគ្រប់ជ្រុងជ្រោយ ដែលការណ៍នេះបានធ្វើឱ្យមានភាពយឺតយ៉ាវក្នុងការដាក់ឱ្យដំណើរការទីផ្សារនាពេលកន្លងមក។

**ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោកស្រី អស់លោក**

ជាថ្មីម្តងទៀត ការសម្ពោធបើកក្រុមហ៊ុនមូលបត្រជាផ្លូវការថ្ងៃនេះ ក៏ជាការឆ្លុះបញ្ចាំងនូវការត្រៀមខ្លួនរបស់ក្រុមហ៊ុនក្នុងការបំពេញតួនាទីយ៉ាងសំខាន់ជាអន្តរការីដើម្បីជួយជំរុញដំណើរការទីផ្សារ និងកៀរគរមូលធនពីវិនិយោគិនតាមយន្តការទីផ្សារផងដែរ។ ហេតុដូចនេះ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាពិសេសរួមចំណែកក្នុងការបង្កើតនិងអភិវឌ្ឍន៍ទីផ្សារមូលបត្រនៅកម្ពុជា ខ្ញុំជឿជាក់ថា ក្រុមហ៊ុនមូលបត្រ Golden Fortune (Cambodia) Securities Plc នឹងបន្តគោរព និងអនុវត្តតាមយ៉ាងខ្ជាប់ខ្ជួននូវលក្ខខណ្ឌអាជ្ញាបណ្ណ ក៏ដូចជាលក្ខខណ្ឌតម្រូវពាក់ព័ន្ធផ្សេងៗ ដែលចេញដោយគណៈកម្មការមូលបត្រកម្ពុជាដែលជានិយ័តករវិស័យមូលបត្រ ព្រមទាំងអាចទាក់ទាញនូវទំនុកចិត្តពីវិនិយោគិនដែលជាចំណុចគន្លឹះឈានទៅរក

ភាពជោគជ័យនៃការប្រកបអាជីវកម្ម និងទីផ្សារមូលបត្រកម្ពុជាយើងទាំងមូល។

ឆ្លៀតក្នុងឱកាសនេះដែរ តាងនាមឲ្យរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្ញុំផ្ទាល់ សូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ និងមូលវិចារដ៏ថ្លៃថ្លាជូនចំពោះលោក **ចាន យុនហ្វេន** គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់របស់ក្រុមហ៊ុនមូលបត្រ Golden Fortune (Cambodia) Securities Plc ដែលបានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្តេចតេជោ ហ៊ុន សែន** ជាប្រមុខដ៏ឆ្នើម ក្នុងកិច្ចអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ក៏ដូចជាសេដ្ឋកិច្ចកម្ពុជាទាំងមូល។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរឲ្យក្រុមហ៊ុនមូលបត្រ Golden Fortune (Cambodia) Securities Plc ប្រកបអាជីវកម្មប្រកបដោយជោគជ័យ រុងរឿង និងរីកចម្រើនទៅថ្ងៃមុខ ព្រមទាំងទទួលបានទំនុកចិត្តខ្ពស់ពីសាធារណជន ជាតិនិងអន្តរជាតិ និងសូមប្រសិទ្ធិពរជូនចំពោះឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោកស្រីអស់លោក ដែលមានវត្តមាននៅក្នុងពិធីនេះ សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ សិរីមង្គល វិបុលសុខ និង ជោគជ័យគ្រប់ភារកិច្ច-ធុរកិច្ច និង**សូមប្រកាសបើកសម្ពោធជាផ្លូវការក្រុមហ៊ុនមូលបត្រ Golden Fortune (Cambodia) Securities Plc ចាប់ពីពេលនេះ តទៅ**។

**សូមអរគុណ !**